**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៤ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍

- បានឃើញអនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០២ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០៤ ស្តីពីការបង្កើតនាយកដ្ឋានស្ថិតិនិងព័ត៌មានទេសចរណ៍នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅដូចខាងក្រោម៖
- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់ក្រសួងទេសចរណ៍
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានានៃក្រសួងទេសចរណ៍
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យទេសចរណ៍។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើវិស័យទេសចរណ៍នៅគ្រប់អង្គភាពថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាលក្រសួងទេសចរណ៍។

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា៤ .-**

ក្រសួងទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥ .-**

ក្រសួងទេសចរណ៍ជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖
- ដឹកនាំ គ្រប់គ្រង សម្របសម្រួល និងអភិវឌ្ឍលើវិស័យទេសចរណ៍
- កំណត់និងរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ សំដៅគ្រប់គ្រងនិងអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រនិងឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ

- រួមចំណែកការពារនិងថែរក្សាធនធានធម្មជាតិ វប្បធម៌ និងទំនៀមទម្លាប់ ដែលជាមូលដ្ឋានបម្រើឱ្យវិស័យទេសចរណ៍
- ទាញយកផលប្រយោជន៍ក្នុងវិស័យទេសចរណ៍ឱ្យបានជាអតិបរមា ធានាការបែងចែកប្រកបដោយសមធម៌និងប្រកបដោយបរិយាបន្ន និងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃវិស័យទេសចរណ៍
- ផ្សព្វផ្សាយវិស័យទេសចរណ៍ក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា
- ចាត់តាំងស្ថានតំណាងទេសចរណ៍នៅក្រៅប្រទេស ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- គ្រប់គ្រងនិងត្រួតពិនិត្យព័ត៌មានទេសចរណ៍
- គ្រប់គ្រងនិងជំរុញចលនាទេសចរណ៍ក្នុងស្រុក
- លើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយ រកទីផ្សារ និងជំរុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន
- អភិវឌ្ឍផលិតផលទេសចរណ៍ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន
- ពង្រឹងការអភិវឌ្ឍអេកូទេសចរណ៍និងសហគមន៍ទេសចរណ៍មូលដ្ឋាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- អភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ឱ្យស្របតាមស្តង់ដាជាតិនិងអន្តរជាតិ អាស៊ាន តំបន់ និងពិភពលោក
- គ្រប់គ្រងនិងត្រួតពិនិត្យសាលាជំនាញវិជ្ជាជីវៈទេសចរណ៍និងគ្រឹះស្ថានអប់រំទេសចរណ៍
- ធានានិងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតប្រព័ន្ធស្តង់ដានានាក្នុងវិស័យទេសចរណ៍និងប្រព័ន្ធធានាគុណភាពដោយផ្តល់សន្តិសុខសុវត្ថិភាព ផាសុកភាព និងបង្កើនការពេញចិត្តដល់ទេសចរ
- គ្រប់គ្រងអាជីវកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងសេវាកម្មផ្សេងទៀត បម្រើឱ្យវិស័យទេសចរណ៍ តាមរយៈការផ្តល់អាជ្ញាបណ្ណទេសចរណ៍
- ត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើអាជីវកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងសេវាកម្មផ្សេងទៀតដែលបម្រើឱ្យវិស័យទេសចរណ៍
- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពលើកកម្ពស់ និងជំរុញចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិក្នុងវិស័យទេសចរណ៍
- សហការគ្រប់គ្រងសមាគមឧស្សាហកម្មទេសចរណ៍
- សហការរួមចំណែកការពារបរិស្ថាននិងលើកកម្ពស់ "កម្ពុជាស្អាត កម្ពុជាបៃតង"
- សហការជំរុញការវិនិយោគវិស័យទេសចរណ៍ ស្របតាមផែនការអភិវឌ្ឍជាតិនិងផែនការអភិវឌ្ឍទេសចរណ៍កម្ពុជា
- សហការជាមួយផ្នែកពាក់ព័ន្ធ ក្នុងការដោះស្រាយវិវាទទេសចរណ៍
- សហការគ្រប់គ្រងនិងឯកជនភាវូបនីយកម្មនៃសហគ្រាសទេសចរណ៍របស់រដ្ឋ

- សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងដីធ្លីរបស់រដ្ឋ ដែលបានផ្តល់សម្រាប់គោលបំណងទេសចរណ៍
- សហការជាមួយនគរបាលទេសចរណ៍និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាសន្តិសុខ សុវត្ថិភាពទេសចរ
- ផ្តល់យោបល់លើផែនការប្រើប្រាស់ដីធ្លី តាមរយៈយន្តការគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផ្តល់យោបល់លើហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ បម្រើឱ្យវិស័យទេសចរណ៍
- ផ្តល់យោបល់លើការផ្តល់សម្បទានសម្រាប់គោលបំណងទេសចរណ៍
- សហការផ្តល់យោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ លើការកសាងគោលនយោបាយពន្ធដារលើអាជីវកម្មទេសចរណ៍ ទិដ្ឋាការ និងគោលនយោបាយអាកាសចរណ៍
- រៀបចំនិងអនុវត្ត សម្របសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរ និងផ្នែកឯកជន ក្នុងការអនុវត្តបទប្បញ្ញត្តិ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

**មាត្រា៦ .–**

ក្រសួងទេសចរណ៍ មានរចនាសម្ព័ន្ធដូចតទៅ៖

**ក- ថ្នាក់កណ្តាល**

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ
- អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- វិទ្យាស្ថានជាតិទេសចរណ៍
- អគ្គាធិការដ្ឋាន
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

**ខ- អង្គភាពមូលដ្ឋាន**

**គ- គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាលរបស់ក្រសួងទេសចរណ៍។**

អង្គការលេខរបស់ក្រសួងទេសចរណ៍ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៧ .–**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី៤
## អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

**មាត្រា៨ .-**

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ជាសេនាធិការឱ្យក្រសួងទេសចរណ៍លើការងាររដ្ឋបាលនិងកិច្ចការទូទៅ ការងារធនធានមនុស្ស ការងារគណនេយ្យនិងហិរញ្ញវត្ថុ ការងារសន្តិសុខនិងសុវត្ថិភាពទេសចរ និងសម្របសម្រួលសកម្មភាពរដ្ឋបាលជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ វិស័យឯកជន និងអង្គភាពថ្នាក់ក្រោមជាតិ ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធការងាររដ្ឋបាលនិងកិច្ចការទូទៅ ការងារធនធានមនុស្ស ការងារគណនេយ្យនិងហិរញ្ញវត្ថុ និងការងារសន្តិសុខ និងសុវត្ថិភាពទេសចរ
- គ្រប់គ្រង ការងាររដ្ឋបាល និងកិច្ចការទូទៅ ការងារធនធានមនុស្ស ការងារគណនេយ្យ និងហិរញ្ញវត្ថុ និងការងារសន្តិសុខ និងសុវត្ថិភាពទេសចរ
- សម្របសម្រួលកិច្ចការរបស់ក្រសួងនៅថ្នាក់កណ្តាលនិងអង្គភាពចំណុះក្រសួងទេសចរណ៍
- គ្រប់គ្រងមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- គ្រប់គ្រងនិងពង្រឹងសន្តិសុខ និងសុវត្ថិភាពទេសចរ
- គ្រប់គ្រងថវិការដ្ឋនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការងាររបស់ក្រសួង ដែលមានរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាអាណាប័ក
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
- នាយកដ្ឋានធនធានមនុស្ស
- នាយកដ្ឋានសន្តិសុខនិងសុវត្ថិភាពទេសចរ
- នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ។

នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៩ .-**

នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការងាររដ្ឋបាលនិងកិច្ចការទូទៅរបស់ក្រសួងទេសចរណ៍
- សម្របសម្រួលកិច្ចការរបស់ក្រសួងនៅថ្នាក់កណ្តាលនិងអង្គភាពចំណុះក្រសួងទេសចរណ៍
- សម្របសម្រួលសកម្មភាពរដ្ឋបាលជាមួយ ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ វិស័យឯកជន និងអង្គភាពថ្នាក់ក្រោមជាតិ
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង

- ធានាប្រសិទ្ធភាពការងារតម្កល់ឯកសារក្នុងក្រសួង និងបញ្ជូនឯកសារតម្កល់ទៅជូនបណ្ណសារដ្ឋាននៃទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់គ្រងរាល់លិខិតស្នាមដែលបញ្ជូនចេញនិងទទួលលិខិតពីបណ្តាក្រសួងស្ថាប័នដទៃទៀត
- លើកផែនការ វិធានការ ព្រមទាំងត្រួតពិនិត្យវិធានការ ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព អនាម័យ និងសោភណភាពរបស់ក្រសួង
- ត្រួតពិនិត្យនិងផ្តល់យោបល់អំពីនីតិវិធីរដ្ឋបាល និងកែទម្រង់លិខិតរដ្ឋបាលរបស់ក្រសួង
- ចរាចរលិខិតឯកសារចូលនិងចេញទៅកាន់គោលដៅក្នុងនិងក្រៅក្រសួង
- សហការជាមួយអង្គភាពជំនាញនិងខុទ្ទកាល័យរដ្ឋមន្ត្រី ក្នុងការរៀបចំរាល់ប្រជុំ សិក្ខាសាលា សន្និបាតនានារបស់ក្រសួង
- សហការជាមួយអង្គភាពជំនាញនិងខុទ្ទកាល័យរដ្ឋមន្ត្រី ក្នុងការរៀបចំគម្រោង កម្មវិធីការងារប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ របស់ថ្នាក់ដឹកនាំក្រសួង
- បង្កើត គ្រប់គ្រង រចនា និងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ក្រសួងទេសចរណ៍
- ធ្វើពិធីការនិងបដិសណ្ឋារកិច្ចជូនថ្នាក់ដឹកនាំក្រសួង និងគណៈប្រតិភូផ្លូវការនានា ព្រមទាំងចូលរួម ព្រះរាជពិធីបុណ្យជាតិ អន្តរជាតិនានា តាមផែនការរបស់ក្រសួង ដែលបានដាក់ចុះ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ និងលើកទិសដៅការងារក្រសួង ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១០.-**

នាយកដ្ឋានធនធានមនុស្ស មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- គ្រប់គ្រងក្របខណ្ឌ រៀបចំផែនការក្របខណ្ឌ និងធនធានមនុស្សរបស់ក្រសួង
- រៀបចំលិខិតរដ្ឋបាលសម្រាប់ការគ្រប់គ្រងក្របខណ្ឌមន្ត្រីរាជការ
- សហការជាមួយនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ បណ្តុះបណ្តាលមន្ត្រីរាជការនៅទីស្តីការក្រសួង និងមន្ទីរទេសចរណ៍រាជធានី ខេត្ត
- សហការរៀបចំការបណ្តុះបណ្តាល តាមដានអនុវត្ត និងវាយតម្លៃការបណ្តុះបណ្តាលមន្ត្រីរាជការ
- រៀបចំស្ថិតិគ្រប់គ្រងមន្ត្រីរាជការនិងតារាងព័ត៌មានការងារមន្ត្រីរាជការ
- រៀបចំក្របខណ្ឌ ដោយផ្អែកលើការសិក្សាវិភាគមុខងារនិងចំនួនមុខតំណែងឱ្យសមស្រប
- រៀបចំលិខិតបទដ្ឋានគតិយុត្ត លើការជ្រើសរើស ការតាំងស៊ប់ក្នុងក្របខណ្ឌ ការរៀបចំបៀវត្សរ៍ ការដំឡើងថ្នាក់និងឋានន្តរសក្តិ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្លាស់ប្តូរ ការផ្ទេរក្របខណ្ឌ ការផ្តល់រង្វាន់ ការផ្តល់គ្រឿងឥស្សរិយយស ការដាក់វិន័យ ការបញ្ចប់ភារកិច្ច ការលុបឈ្មោះ ឬបញ្ឈប់ពីការងារ ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរ៍ ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម និងការដាក់ឱ្យចូលនិវត្តន៍ ឬបាត់បង់សម្បទាវិជ្ជាជីវៈនៃមន្ត្រីរាជការ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១១ .-**

នាយកដ្ឋានសន្តិសុខនិងសុវត្ថិភាពទេសចរ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងសន្តិសុខនិងសុវត្ថិភាពទេសចរ
- រៀបចំផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងវិធានការចាំបាច់នានា ក្នុងការពង្រឹងសន្តិសុខនិងសុវត្ថិភាពទេសចរ
- ផ្សព្វផ្សាយ ណែនាំ និងជំរុញឱ្យគ្រប់អាជីវកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងសេវាផ្សេងទៀតបម្រើឱ្យវិស័យទេសចរណ៍ ដើម្បីបង្កើនការការពារសន្តិសុខនិងសុវត្ថិភាពទេសចរ
- ជំរុញនិងត្រួតពិនិត្យប្រព័ន្ធសន្តិសុខ សុវត្ថិភាព និងសម្បទាទេសចរណ៍នៃមូលដ្ឋានអាជីវកម្មនិងសេវាកម្មទេសចរណ៍
- សហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសុខាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គភាពនៅថ្នាក់ក្រោមជាតិ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងវិស័យឯកជន រៀបចំវិធានការ និងយន្តការចាំបាច់ទាក់ទងការរក្សាសន្តិសុខ និងសុវត្ថិភាពជូនទេសចរ
- សហការជាមួយស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ដើម្បីបង្កើតនិងពង្រឹងប្រព័ន្ធសង្គ្រោះទេសចរបឋមនិងបន្ទាន់ ព្រមទាំងប្រព័ន្ធសុវត្ថិភាពទេសចរផ្សេងៗទៀត
- សហការជាមួយសមត្ថកិច្ចនគរបាលទេសចរណ៍លើការងារពង្រឹងសន្តិសុខ សុវត្ថិភាពទេសចរ និងជំរុញឲ្យមានសន្តិសុខស្ម័គ្រចិត្តឯកជននៅតាមតំបន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍នានា
- ជាលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិនិងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១២ .-**

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងថវិការដ្ឋនិងហិរញ្ញវត្ថុសម្រាប់ដំណើរការងាររបស់ក្រសួង ដែលមានរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាអាណាប័ក
- លើកគម្រោងនិងការអនុវត្តថវិការដ្ឋប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំយុទ្ធសាស្ត្រ ផែនការថវិការបស់ក្រសួងទេសចរណ៍
- ប្រមូលផ្តុំតម្រូវការ រៀបចំរបាយការណ៍ប្រាក់ចំណូលបង់ចូលថវិការដ្ឋ ស្របតាមច្បាប់ហិរញ្ញវត្ថុ
- ធ្វើកម្មវិធីចំណាយ គ្រប់គ្រងសម្ភារៈ បរិក្ខារ រៀបចំការងារជួសជុលតូច ធំ និងសាងសង់
- ប្រមូលផ្តុំនិងសម្របសម្រួលរាល់ការចំណាយថវិការបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យនិងអចលនទ្រព្យ សន្និធិ សម្ភារៈ ប្រេងឥន្ធនៈ
- ធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងបញ្ជីជាប្រចាំនូវសេលាកបត្រនិងគណនេយ្យរូបធាតុ
- រៀបចំនិងបើកប្រាក់បៀវត្សរ៍និងប្រាក់សង្គមកិច្ចជូនមន្ត្រីរាជការ

- រៀបចំព័ត៌មានវិទ្យានៃសកម្មភាពហិរញ្ញវត្ថុនិងបន្ទុកគណនី
- លើកគម្រោងផែនការសេដ្ឋកិច្ច សង្គមកិច្ច និងវិនិយោគសាធារណៈរបស់ក្រសួង
- លើកគម្រោងផែនការក្រសួង និងតាមដានរំលឹកពីការអនុវត្តថវិកា និងគ្រប់គ្រងគណនីរបស់ក្រសួង
- តាមដានរបាយការណ៍នៃចលនាចំណូល ចំណាយថវិការបស់មន្ទីរទេសចរណ៍រាជធានី ខេត្ត
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ

**មាត្រា១៣ .-**

អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ ជាសេនាធិការឱ្យក្រសួងទេសចរណ៍ ក្នុងការធ្វើផែនការ ជំរុញ និងអភិវឌ្ឍទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការជំរុញនិងការអភិវឌ្ឍវិស័យទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ
- ជំរុញកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយអង្គការទេសចរណ៍ពិភពលោក អង្គការអន្តរជាតិនានា និងរវាងបណ្តាប្រទេសជាសមាជិកអាស៊ាន និងប្រទេសនានាក្នុងតំបន់និងពិភពលោក
- រៀបចំ ពិនិត្យ និងផ្តល់យោបល់ក្នុងការទាក់ទាញ ជំរុញសកម្មភាពអាជីវកម្មលើវិស័យទេសចរណ៍
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លី និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទេសចរណ៍
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការផ្តល់យោបល់លើគោលនយោបាយពន្ធដារ ទិដ្ឋាការ និងអាកាសចរណ៍
- ពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធក្នុងការផ្តល់ភាពជាម្ចាស់កម្មសិទ្ធិ ភតិសន្យា ឬសម្បទានសម្រាប់គោលបំណងទេសចរណ៍
- ជំរុញការសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស
- គ្រប់គ្រងនិងត្រួតពិនិត្យព័ត៌មានទេសចរណ៍ក្រៅប្រទេស
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ មាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍
- នាយកដ្ឋានវិនិយោគទេសចរណ៍
- នាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍

- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន
- នាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស។

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៤ .-**

នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ រៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ក្រោមជាតិ
- សហការរៀបចំផែនការទេសចរណ៍ផ្ទះទីពីរ ទេសចរណ៍វ៉ៃយចំណាស់ និងប្រភេទទេសចរណ៍ផ្សេងទៀត និងផែនការប្រើប្រាស់ដីធ្លីសម្រាប់វិស័យទេសចរណ៍
- ពិគ្រោះយោបល់លើគោលនយោបាយអាកាសចរណ៍ ទិដ្ឋាការ គោលនយោបាយការប្រើប្រាស់ដីធ្លី ផែនការរូបវន្ត និងផែនការអភិវឌ្ឍន៍
- សហការរៀបចំ បង្កើត និងធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍ទេសចរណ៍ដើម្បីគ្រួតពិនិត្យ កែលម្អ និងរក្សាបានការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជាប្រកបដោយគុណភាព និរន្តរភាព និងការទទួលខុសត្រូវ
- សហការរៀបចំយុទ្ធសាស្ត្រជំរុញការកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងបណ្តាប្រទេសក្នុងតំបន់ ដើម្បីសិក្សាស្រាវជ្រាវ រៀបចំគម្រោងអភិវឌ្ឍន៍ និងជំរុញកិច្ចសហប្រតិបត្តិទេសចរណ៍ក្នុងក្របខណ្ឌតំបន់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញនិងវាយតម្លៃការអនុវត្តផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍
- ជាលេខាធិការដ្ឋានរបស់គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍
- ផ្តល់យោបល់ផ្នែកជំនាញដល់ការរៀបចំផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងផ្នែកឯកជន ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពរាល់គម្រោងអភិវឌ្ឍន៍នានា ដែលបម្រើឱ្យវិស័យទេសចរណ៍ ឱ្យស្របតាមផែនការអភិវឌ្ឍន៍ទេសចរណ៍
- ស្វែងរកជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ និងផ្នែកពាក់ព័ន្ធដើម្បីជំរុញការអភិវឌ្ឍទេសចរណ៍នៅកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១៥ .-**

នាយកដ្ឋានវិនិយោគទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការងារវិនិយោគទេសចរណ៍
- រៀបចំផែនការយុទ្ធសាស្ត្រដើម្បីសហការទាក់ទាញនិងជំរុញការវិនិយោគលើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា

- សិក្សានិងរៀបចំបញ្ជីសក្តានុពលវិនិយោគទេសចរណ៍ និងធ្វើបច្ចុប្បន្នកម្មលើទិន្នន័យ និងស្ថិតិនៃគម្រោងវិនិយោគក្នុងវិស័យទេសចរណ៍
- សហការពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃលើគម្រោងវិនិយោគលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌនៃយន្តការច្រកចេញចូលតែមួយរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សហការផ្តល់យោបល់ជំនាញលើការផ្តល់ឱ្យភាពជាម្ចាស់កម្មសិទ្ធិ ភតិសន្យា ឬសម្បទានសម្រាប់គោលបំណងនៃការវិនិយោគទេសចរណ៍
- អនុវត្តគម្រោងវិនិយោគសាធារណៈ ដោយសហការជាមួយផ្នែកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានដែលបណ្តាលមកពីគម្រោងវិនិយោគនានាក្នុងវិស័យទេសចរណ៍
- សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីជំរុញការវិនិយោគលើវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១៦ .-**

នាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវនិងរៀបចំផែនការយុទ្ធសាស្ត្រ បង្កើត គ្រប់គ្រង និងអភិវឌ្ឍផលិតផលទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ បេតិកភណ្ឌ និងធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការរៀបចំផែនការយុទ្ធសាស្ត្រអេកូទេសចរណ៍ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រកម្ពុជានិងអេកូទេសចរណ៍
- ជំរុញ បង្កើត អនុវត្ត និងត្រួតពិនិត្យលើរមណីយដ្ឋានទេសចរណ៍វប្បធម៌ ធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិ-ទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀត
- កំណត់យន្តការនិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីពិនិត្យ និងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ក្នុងការផ្តល់ ការបន្តការលុបចោល ឬការព្យួរអាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្មរមណីយដ្ឋានទេសចរណ៍វប្បធម៌ ធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិ-ទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀត
- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ស្តង់ដាអប្បបរមា និងការអនុវត្តនានា ដើម្បីតាមដាន ត្រួតពិនិត្យ កែលម្អ និងរក្សាគុណភាពរមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្របេតិកភណ្ឌ និងធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិ-ទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀតនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិឱ្យស្របតាមស្តង់ដាជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការសិក្សាស្រាវជ្រាវប្រវត្តិរមណីយដ្ឋាន ប្រវត្តិវប្បធម៌ប្រពៃណី ទំនៀមទម្លាប់ ដើម្បីចងក្រងជាឯកសារ និងរៀបចំធ្វើជាព្រឹត្តិការណ៍ទេសចរណ៍នៅតាមរាជធានី ខេត្ត និងគោលដៅទេសចរណ៍

- ចូលរួមជំរុញនិងអនុវត្តចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ និងអង្គភាពពាក់ព័ន្ធក្នុងការអភិវឌ្ឍផលិតផលទេសចរណ៍
- សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈក្នុងការពិនិត្យលើផ្នែកសំណង់ស្ថាបត្យកម្មទេសចរណ៍ ឱ្យស្របទៅតាមរចនាបថខ្មែរ ទាំងការតុបតែងលំអ ការប្រគុំតន្ត្រីបុរាណ សម្លៀកបំពាក់តាមបែបបុរាណខ្មែរ ទាំងការប្រើប្រាស់ផលិតផលក្នុងស្រុក នៅតាមមូលដ្ឋានអាជីវកម្មនិងសេវាកម្មទេសចរណ៍ដោយរក្សាបាននូវអត្តសញ្ញាណជាតិ
- សហការត្រួតពិនិត្យការលក់ដូរវត្ថុអនុស្សាវរីយ៍ដល់ភ្ញៀវទេសចរ
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានដែលបណ្តាលមកពីការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ បេតិកភណ្ឌ និងធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិ-ទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀត
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១៧ .-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពនិងការអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន
- សហការសិក្សាស្រាវជ្រាវ រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាននិងអន្តរជាតិ
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី អាស៊ាន និងអន្តរជាតិ
- គ្រប់គ្រង វិភាគ និងតាមដានសភាពការណ៍ក្នុងកិច្ចការអាស៊ាន និងអន្តរជាតិក្នុងវិស័យទេសចរណ៍
- សម្របសម្រួលការរៀបចំនិងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ និងឯកសារគតិយុត្តនានាជាមួយស្ថាប័នទេសចរណ៍អាស៊ាននិងអន្តរជាតិ
- សហការរៀបចំកិច្ចប្រជុំ ព្រឹត្តិការណ៍ទេសចរណ៍ និងសន្និសីទទេសចរណ៍ថ្នាក់អាស៊ាន តំបន់ និងអន្តរជាតិ
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងវិបត្តិ និងហានិភ័យនៅក្នុងវិស័យទេសចរណ៍ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាននិងអន្តរជាតិ
- សហការទាក់ទាញ ជំរុញវិនិយោគ និងស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីបរទេសសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១៨ .-**

នាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេសមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សហការរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងកម្មវិធីនានាពាក់ព័ន្ធនឹងការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស
- សិក្សាទីផ្សារនិងជំរុញការទាក់ទាញទេសចរមកកម្ពុជា
- ផ្សព្វផ្សាយអំពីទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារទេសចរណ៍អន្តរជាតិ
- សម្របសម្រួលនិងរៀបចំកម្មវិធីទស្សនកិច្ចសម្រាប់ភ្នាក់ងារសារព័ត៌មាន ប្រតិបត្តិករទេសចរណ៍ និងវិនិយោគិនបរទេសដែលមកធ្វើទស្សនកិច្ចសិក្សាស្វែងយល់និងផ្សព្វផ្សាយគោលដៅទេសចរណ៍កម្ពុជានៅលើទីផ្សារទេសចរណ៍អន្តរជាតិ
- រៀបចំនិងចូលរួមក្នុងពិព័រណ៍ទេសចរណ៍អន្តរជាតិនានា
- រៀបចំ បង្កើត និងគ្រប់គ្រងស្ថានតំណាងទេសចរណ៍កម្ពុជានៅលើទីផ្សារអន្តរជាតិ
- ចងក្រងនិងផលិតឯកសារផ្សព្វផ្សាយទេសចរណ៍សម្រាប់ទីផ្សារអន្តរជាតិ
- ធ្វើការកែសម្រួលនិងឆ្លើយតបឱ្យបានទាន់ពេលវេលាទាក់ទិននឹងព័ត៌មាននានា និងការផ្សព្វផ្សាយមិនប្រក្រតីអំពីវិស័យទេសចរណ៍កម្ពុជានៅក្នុងទីផ្សារអន្តរជាតិ
- សហការរៀបចំទេសចរណ៍-MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រឹត្តិការណ៍ទេសចរណ៍នានាកម្រិតអន្តរជាតិនិងតំបន់ ដើម្បីជំរុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ
- ជាលេខាធិការដ្ឋានឲ្យក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី៦
## អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

**មាត្រា១៩ .-**

អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ជាសេនាធិការឱ្យក្រសួងទេសចរណ៍ និងជាអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ដែលទទួលបន្ទុកគ្រប់គ្រង និងសម្របសម្រួលការងារក្នុងឧស្សាហកម្មទេសចរណ៍ និងទទួលខុសត្រូវក្នុងការជំរុញចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"។

អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងទ្រទ្រង់ចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- ប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងទិន្នន័យឧស្សាហកម្មទេសចរណ៍ដោយធ្វើទំនើបកម្មស្របតាមការវិវឌ្ឍនៃប្រព័ន្ធបច្ចេកវិទ្យា
- ពិនិត្យលើការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មូលដ្ឋានអាជីវកម្ម និងសេវាកម្មផ្សេងទៀតដែលបម្រើឲ្យវិស័យទេសចរណ៍

- ធានានិងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍ តាមរយៈការបង្កើតប្រព័ន្ធធានាគុណភាព ប្រព័ន្ធចំណាត់ថ្នាក់ ប្រព័ន្ធស្តង់ដា និងប្រព័ន្ធផ្សេងទៀតដែលបម្រើឲ្យឧស្សាហកម្មទេសចរណ៍
- ជំរុញការសិក្សានិងផ្សព្វផ្សាយទេសចរណ៍ក្នុងប្រទេស
- គ្រប់គ្រងនិងត្រួតពិនិត្យព័ត៌មានទេសចរណ៍ក្នុងប្រទេស
- រៀបចំផែនការនិងកម្មវិធីនានាសំដៅគ្រប់គ្រងធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
- ត្រួតពិនិត្យការទទួលស្គាល់និងតាមដានការអនុវត្តសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ គ្រឹះស្ថានអប់រំក្នុងវិស័យទេសចរណ៍ និងការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍
- គ្រប់គ្រង ត្រួតពិនិត្យ និងបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍
- រៀបចំផែនការនិងលើកកម្ពស់ការយល់ដឹងជាសាធារណៈក្នុងវិស័យទេសចរណ៍ និងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- សម្របសម្រួលជាមួយក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី ខេត្ត
- សម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនិងបង្កើនប្រសិទ្ធភាពការងារ គ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- ណែនាំផ្នែកជំនាញបច្ចេកទេសដល់មន្ទីរទេសចរណ៍រាជធានី ខេត្ត
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ មាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ
- នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារដឹកជញ្ជូននិងមគ្គុទ្ទេសក៍ទេសចរណ៍
- នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍
- នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
- នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុកនិងអប់រំការយល់ដឹងជាសាធារណៈ
- នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត
- នាយកដ្ឋានសេវាគាំពារទីក្រុងស្អាតនិងជំរុញការប្រឡងប្រណាំង។

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា២០ ...**

នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងត្រួតពិនិត្យលើរាល់អាជីវកម្ម និងសេវាកម្មទាក់ទងនឹងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ទេសចរណ៍-MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា

- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ប្រព័ន្ធចំណាត់ថ្នាក់ ស្តង់ដាអប្បបរមា និងការអនុវត្តនានា ដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងរក្សាគុណភាពសេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ ទេសចរណ៍-MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិឱ្យស្របតាមកម្រិតស្តង់ដាជាតិ អន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កំណត់យន្តការនិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុបចោល ឬការព្យួរអាជ្ញាបណ្ណទេសចរណ៍ ទាំងការសុំបិទអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ ទេសចរណ៍-MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍)ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា
- ពង្រឹងនិងជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុកសំដៅបង្កើនតម្លៃបន្ថែមក្នុងវិស័យទេសចរណ៍ឱ្យបានជាអតិបរមា
- សហការជាមួយផ្នែកឯកជននិងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើតស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ និងការលើកទឹកចិត្ត
- សហការជាមួយផ្នែកឯកជននិងផ្នែកពាក់ព័ន្ធដើម្បីពង្រឹងគុណភាពសេវាកម្មស្នាក់នៅនិងម្ហូបអាហារ ទេសចរណ៍-MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា និងការអនុវត្តរបស់សមាគមដែលពាក់ព័ន្ធនឹងសេវាកម្មស្នាក់នៅនិងម្ហូបអាហារទេសចរណ៍-MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា
- សហការជំរុញនិងកំណត់យន្តការក្នុងការរក្សាអនាម័យនិងសុវត្ថិភាពចំណីអាហារទាំងក្នុងភោជនីយដ្ឋាន អាហារដ្ឋាន ទាំងក្នុងទីសាធារណៈ
- សហការជាមួយនឹងសមាគមក្នុងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ទេសចរណ៍-MICE(ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ាដើម្បីរៀបចំបង្កើតនិងបំផុសឲ្យមានការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅ ទេសចរណ៍ និងម្ហូបអាហារ ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានដែលបណ្តាលមកពីការធ្វើអាជីវកម្ម លើសេវាកម្មស្នាក់នៅ ទេសចរណ៍ និងម្ហូបអាហារ ទេសចរណ៍-MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**មាត្រា២១ .-**

នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងត្រួតពិនិត្យលើរាល់អាជីវកម្មនិងសេវាកម្មទាក់ទងនឹងទីភ្នាក់ងារទេសចរណ៍ ដឹកជញ្ជូនទេសចរ និងមគ្គុទ្ទេសក៍ទេសចរណ៍

- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ប្រព័ន្ធចំណាត់ថ្នាក់ ស្តង់ដាអប្បបរមា និងការអនុវត្តនានាដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងរក្សាគុណភាពសេវាកម្មទីភ្នាក់ងារដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិឱ្យស្របតាមកម្រិតស្តង់ដាជាតិ អន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កំណត់យន្តការនិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុបចោល ឬការព្យួរអាជ្ញាបណ្ណទេសចរណ៍ ទាំងការសុំបិទអាជីវកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- គ្រប់គ្រងប្រព័ន្ធតាមដាននិងត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់កម្រិត ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សហការជំរុញផែនផលិតកម្មទេសចរណ៍ បង្កើត និងបង្កើនខ្សែទស្សនកិច្ចទេសចរណ៍ដើម្បីឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ដ៏សំបូរបែប
- សហការជាមួយនឹងសមាគមក្នុងសេវាកម្មទីភ្នាក់ងារទេសចរណ៍ សមាគមដឹកជញ្ជូនទេសចរណ៍ និងសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ដើម្បីរៀបចំបង្កើត និងបំផុសឲ្យមានការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- សហការជាមួយផ្នែកឯកជនដើម្បីពង្រឹងគុណភាពសេវាកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ និងការអនុវត្តរបស់សមាគមដែលពាក់ព័ន្ធនឹងសេវាកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- សហការធានាសន្តិសុខ សុវត្ថិភាព និងសេវាកម្មប្រកបដោយគុណភាព និងភាពពេញចិត្តរបស់ទេសចរ
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានដែលបណ្តាលមកពីការធ្វើអាជីវកម្ម ទីភ្នាក់ងារទេសចរណ៍ សេវាកម្មដឹកជញ្ជូន ទេសចរណ៍ និងមគ្គុទ្ទេសក៍ទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**មាត្រា២២ .-**

នាយកដ្ឋានគ្រប់គ្រងសេវាកម្មភោជនីយដ្ឋាននិងកីឡាទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង ត្រួតពិនិត្យលើរាល់អាជីវកម្មនិងសេវាកម្មទាក់ទងនឹងសេវាកម្មភោជនីយដ្ឋាននិងកីឡាទេសចរណ៍
- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ស្តង់ដាអប្បបរមា និងការអនុវត្តនានាដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងរក្សាគុណភាពសេវាកម្មភោជនីយដ្ឋាន និងកីឡាទេសចរណ៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យស្របតាមកម្រិតស្តង់ដាជាតិ អន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កំណត់យន្តការនិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុបចោល ឬការព្យួរអាជ្ញាបណ្ណទេសចរណ៍ ទាំងការសុំបិទអាជីវកម្មសេវាកម្មភោជនីយដ្ឋាននិងកីឡាទេសចរណ៍
- សហការជំរុញ ណែនាំវិធានការ និងរៀបចំកម្មវិធីផ្សព្វផ្សាយសំដៅលើកកម្ពស់ និងបង្កើនការធានាគុណភាព និងអភិវឌ្ឍអាជីវកម្មសេវាកម្មភោជនីយដ្ឋាននិងកីឡាទេសចរណ៍

- សហការជាមួយនឹងសមាគមក្នុងសេវាកម្មសេវាកម្សាន្តនិងកីឡាទេសចរណ៍ ដើម្បីរៀបចំបង្កើត និងបំផុសឲ្យមានការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មសេវាកម្សាន្ត និងកីឡាទេសចរណ៍
- សហការជាមួយផ្នែកឯកជនដើម្បីពង្រឹងគុណភាពសេវាកម្សាន្តនិងកីឡាទេសចរណ៍ និងការអនុវត្តរបស់សមាគមដែលពាក់ព័ន្ធនឹងសេវាកម្សាន្តនិងកីឡាទេសចរណ៍
- សហការសិក្សាផលប៉ះពាល់អវិជ្ជមានដល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានដែលបណ្តាលមកពីការធ្វើអាជីវកម្មសេវាកម្សាន្តនិងអភិវឌ្ឍកីឡាទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**មាត្រា២៣ .-**

នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្របណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍និងបដិសណ្ឋារកិច្ច
- ត្រួតពិនិត្យលើរាល់សាលាជាតិបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលគ្រប់គ្រងដោយរដ្ឋ
- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ស្តង់ដាអប្បបរមា កម្មវិធីសិក្សា ស្តង់ដាសមត្ថភាពជំនាញវិជ្ជាជីវៈ និងការអនុវត្តនានាដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងរក្សាគុណភាពអប់រំបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ឱ្យស្របតាមកម្រិតជាតិនិងអន្តរជាតិ អាស៊ាន តំបន់ និងពិភពលោក និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការគ្រប់គ្រង ត្រួតពិនិត្យ ទទួលស្គាល់រាល់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍គ្រប់គ្រងដោយឯកជន និងអង្គការមិនមែនរដ្ឋាភិបាល លើកម្មវិធីសិក្សា ស្របតាមកម្មវិធីសិក្សាជាតិ អាស៊ាន និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយក្រសួង ស្ថាប័ន ផ្នែកពាក់ព័ន្ធ ដើម្បីបញ្ចូលកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍នៅតាមគ្រឹះស្ថានអប់រំនានា
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័ន ផ្នែកពាក់ព័ន្ធក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍
- សហការជាមួយនាយកដ្ឋានធនធានមនុស្ស នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន និងភាគីពាក់ព័ន្ធ រៀបចំផែនការយុទ្ធសាស្ត្រ និងស្វែងរកជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីធ្វើការបណ្តុះបណ្តាលមន្ត្រីរាជការនៅទីស្តីការក្រសួង និងមន្ទីរទេសចរណ៍រាជធានី ខេត្ត
- ជាលេខាធិការដ្ឋានឱ្យគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- សហការអនុវត្តវិធានការនិងរៀបចំកម្មវិធីបណ្តុះបណ្តាលនានាសំដៅលើកកម្ពស់និងធានាគុណភាពធនធានមនុស្សក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**មាត្រា២៤ .-**

នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុកនិងអប់រំការយល់ដឹងជាសាធារណៈ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈអំពីវិស័យទេសចរណ៍ដល់សាធារណជន

- ផលិតស្បៀតនិងឯកសារនានាពាក់ព័ន្ធនឹងទេសចរណ៍ ដើម្បីធ្វើការផ្សព្វផ្សាយនិងជំរុញទេសចរណ៍ក្នុងស្រុកឲ្យកាន់តែទូលំទូលាយ
- រៀបចំនិងផ្សព្វផ្សាយព័ត៌មានអប់រំការយល់ដឹងជាសាធារណៈទាក់ទងនឹងកិច្ចអភិវឌ្ឍវិស័យទេសចរណ៍ ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ
- គ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យនិងតាមដានព័ត៌មានទេសចរណ៍កម្ពុជាដែលធ្វើការផ្សព្វផ្សាយជាសាធារណៈ
- សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ក្នុងការជំរុញនិងរៀបចំខ្សែទស្សនកិច្ចតាមគោលដៅទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយផ្នែកផ្សព្វផ្សាយព័ត៌មាននិងអង្គភាពពាក់ព័ន្ធផ្សេងទៀត ក្នុងការបញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីវិស័យទេសចរណ៍តាមគ្រប់រូបភាពនិងគ្រប់មធ្យោបាយ
- សហការអភិវឌ្ឍ ផ្សព្វផ្សាយ និងថែរក្សាគេហទំព័ររបស់ក្រសួងទេសចរណ៍ឱ្យទូលំទូលាយ
- សហការរៀបចំនិងបង្កើតទេសចរណ៍-MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) និងព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗក្នុងប្រទេស
- សហការជាមួយសមាគមទីភ្នាក់ងារទេសចរណ៍និងភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍ដើម្បីសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ក្នុងស្រុក
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**មាត្រា២៥ .-**

នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធចលនាប្រឡងប្រណាំងទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- ពិនិត្យនិងវាយតម្លៃទីក្រុងបេក្ខភាពស្របតាមស្តង់ដាទីក្រុងស្អាត
- រៀបចំ ជំរុញ ពិនិត្យ និងវាយតម្លៃទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- រៀបចំ អង្កេត និងវាយតម្លៃការអនុវត្តផែនការនិងគម្រោងអភិវឌ្ឍន៍ការងារប្រឡងប្រណាំងទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- ពិនិត្យនិងលើកដំណោះស្រាយករណីមិនប្រក្រតីនៃការអនុវត្តរបស់ទីក្រុង ទីប្រជុំជន និងគោលដៅទេសចរណ៍ជ័យលាភី
- សិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគទិន្នន័យ និងឯកសារដែលពាក់ព័ន្ធនឹងការងារវាយតម្លៃទីក្រុង ស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- រៀបចំប្រព័ន្ធគ្រប់គ្រងនិងបញ្ចូលទិន្នន័យពាក់ព័ន្ធនឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- រៀបចំផែនការសកម្មភាព កម្មវិធីអនុវត្តនានា ទ្រទ្រង់ចលនាប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន
- សម្របសម្រួលនិងធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសមាជិកអាស៊ានលើរាល់សកម្មភាពដែលទាក់ទងនឹងចលនាប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន

- សហការរៀបចំនិងវាយតម្លៃតម្រូវការសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្ស និងគ្រប់ភាគីពាក់ព័ន្ធក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត និងចលនាប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**មាត្រា២៦ .-**

នាយកដ្ឋានសេវាគាំពារទីក្រុងស្អាតនិងជំរុញការប្រឡងប្រណាំង មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ កសាង និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តនានា ឯកសារស្តង់ដាធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ បម្រើឱ្យចលនាប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ និងស្តង់ដាបដិសណ្ឋារកិច្ចល្អបម្រើឱ្យចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ"
- រៀបចំគម្រោងសហប្រតិបត្តិការជាមួយនឹងអង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ ដើម្បីទ្រទ្រង់ចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ" ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- រៀបចំគម្រោងគាំទ្រនានាទ្រទ្រង់ដល់ចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- ជំរុញការចូលរួមពីសាធារណជន និងគ្រប់ភាគីពាក់ព័ន្ធក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- រៀបចំនិងដំណើរការមជ្ឈមណ្ឌលទ្រទ្រង់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- រៀបចំការបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពដល់មន្ត្រីវាយតម្លៃទីក្រុងស្អាត មន្ត្រីក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី ខេត្ត
- បង្កើត គ្រប់គ្រង រចនា និងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ **គ.ជ.ទ.ស.** គេហទំព័រធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ និងគេហទំព័រ "បដិសណ្ឋារកិច្ចល្អ"
- រៀបចំ ពិនិត្យ និងចងក្រងគ្រប់ឯកសារផ្សព្វផ្សាយអំពីចលនាប្រឡងប្រណាំងទីក្រុងស្អាត អំពីសកម្មភាពរបស់ **គ.ជ.ទ.ស.** និងអំពីធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- សហការជាមួយស្ថាប័នរដ្ឋ ឯកជន អង្គការ សមាគមជាតិ អន្តរជាតិ វិទ្យាស្ថានសិក្សាស្រាវជ្រាវជាតិ អន្តរជាតិ បណ្តាញធុរកិច្ចបៃតង គ្រឹះស្ថានឧត្តមសិក្សានានា សំដៅពង្រឹងនិងពង្រីកការងារស្រាវជ្រាវនិងការផ្សព្វផ្សាយ "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" ឱ្យបានទូលំទូលាយ ព្រមទាំងជំរុញការអភិវឌ្ឍសមត្ថភាពផ្នែកធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ដល់គ្រប់ភាគីពាក់ព័ន្ធ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

# ជំពូកទី៧
# វិទ្យាស្ថានជាតិទេសចរណ៍

**មាត្រា២៧ .-**

វិទ្យាស្ថានជាតិទេសចរណ៍ជាមណ្ឌលសិក្សានិងជាសេនាធិការឱ្យក្រសួងទេសចរណ៍ ក្នុងការសិក្សា និងស្រាវជ្រាវវិស័យទេសចរណ៍ក្នុងគោលបំណងបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព និងសហការជាមួយផ្នែកពាក់ព័ន្ធក្នុងការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ទេសចរណ៍ ការជំរុញរៀបចំផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ ចូលរួមធ្វើការកែសម្រួល វាយតម្លៃការអនុវត្តការងារទេសចរណ៍ឱ្យចំទិសដៅ និរន្តរភាព និងប្រសិទ្ធភាព ព្រមទាំងជាមជ្ឈមណ្ឌលសម្រាប់ប្រមូលផ្តុំនូវធនធានបញ្ញាញាណ បទពិសោធ និងចំណេះដឹងទេសចរណ៍។

វិទ្យាស្ថានជាតិទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំ ជំរុញការងារស្ថិតិទេសចរណ៍
- សិក្សាស្រាវជ្រាវ វិភាគទេសចរណ៍ សិក្សាវិភាគផលប៉ះពាល់នៃវិស័យទេសចរណ៍ លើសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន និងការទទួលរងផលប៉ះពាល់ពីវិស័យផ្សេងៗលើវិស័យទេសចរណ៍
- រៀបចំគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យទេសចរណ៍
- ជាសេនាធិការឲ្យក្រសួងទេសចរណ៍ក្នុងការវិភាគនិងផ្តល់យោបល់ដល់ស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍
- សហការជាមួយវិទ្យាស្ថានទេសចរណ៍អន្តរជាតិ និងគ្រឹះស្ថានសិក្សាទេសចរណ៍នៅទូទាំងប្រទេស
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី។

វិទ្យាស្ថានជាតិទេសចរណ៍ ដឹកនាំដោយនាយកវិទ្យាស្ថានមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយនាយករងវិទ្យាស្ថានមួយចំនួន មានឋានៈស្មើអគ្គនាយករង អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

វិទ្យាស្ថានជាតិទេសចរណ៍ មាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានស្ថិតិទេសចរណ៍
- នាយកដ្ឋានសិក្សាស្រាវជ្រាវនិងគោលនយោបាយទេសចរណ៍។

នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋាន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

វិទ្យាស្ថានជាតិទេសចរណ៍អាចបង្កើតបណ្ណាល័យសភាទេសចរណ៍មួយ ដែលត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា២៨ .-**

នាយកដ្ឋានស្ថិតិទេសចរណ៍មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងគ្រប់គ្រងការងារស្ថិតិទេសចរណ៍នៅទូទាំងប្រទេស
- ប្រមូល រៀបចំ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិទេសចរណ៍ផ្លូវការនិងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិទេសចរណ៍

- សិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យស្ថិតិទេសចរណ៍ និងចងក្រងស្ថិតិទេសចរណ៍តាមវិធីសាស្ត្រផ្សេងៗ ដើម្បីបង្កើនគុណភាពស្ថិតិទេសចរណ៍ផ្លូវការ
- អង្កេតភ្ញៀវទេសចរ កម្លាំងពលកម្ម និងធនធានទេសចរណ៍
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គភាពស្ថិតិ អាជ្ញាធរពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងផ្នែកឯកជន លើការងារស្ថិតិទេសចរណ៍
- រៀបចំនិងអភិវឌ្ឍប្រព័ន្ធទេសចរណ៍រណប
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់នាយកវិទ្យាស្ថានជាតិទេសចរណ៍។

**មាត្រា២៩ .-**

នាយកដ្ឋានសិក្សាស្រាវជ្រាវនិងគោលនយោបាយទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ វិភាគពីវិស័យទេសចរណ៍និងវិស័យពាក់ព័ន្ធ ក្នុងសមត្ថកិច្ចពិគ្រោះយោបល់របស់ក្រសួងទេសចរណ៍ ដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍
- សិក្សាស្រាវជ្រាវនិងវិភាគអំពីផលប៉ះពាល់នៃការអភិវឌ្ឍវិស័យទេសចរណ៍ ស្ថានភាពទេសចរណ៍ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកំណត់តំបន់ទេសចរណ៍ដែលមានសក្តានុពល ដើម្បីអភិវឌ្ឍឱ្យក្លាយទៅជាគោលដៅទេសចរណ៍
- ព្យាករណ៍តម្រូវការហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ដទៃទៀតដែលបម្រើឱ្យវិស័យទេសចរណ៍
- សិក្សាស្រាវជ្រាវ វិភាគពីផលប្រយោជន៍វិស័យទេសចរណ៍ ផលប៉ះពាល់វិជ្ជមាន អវិជ្ជមាននៃវិស័យនេះមកលើសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន
- សិក្សាស្រាវជ្រាវ វិភាគអំពីការទទួលរងនូវផលប៉ះពាល់ពីវិស័យដទៃមកលើវិស័យទេសចរណ៍
- សហការជាមួយអង្គការទេសចរណ៍ជាតិ អន្តរជាតិ ធ្វើការសិក្សាស្រាវជ្រាវពីសារប្រយោជន៍របស់វិស័យទេសចរណ៍និងនិន្នាការវិវឌ្ឍទេសចរណ៍ថ្មីៗក្នុងតំបន់និងអន្តរជាតិ
- ចូលរួមសហការជាមួយផ្នែកពាក់ព័ន្ធ ក្នុងការជំរុញកិច្ចអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពក្នុងវិស័យទេសចរណ៍
- ប្រមូលផ្តុំធនធានបញ្ញាញាណទេសចរណ៍ បទពិសោធ ចំណេះដឹងទេសចរណ៍ ដើម្បីជំរុញការអភិវឌ្ឍវិស័យទេសចរណ៍
- សម្របសម្រួល តម្រង់ទិស សហការជាមួយគ្រឹះស្ថានសិក្សាទេសចរណ៍ទាំងអស់នៅទូទាំងប្រទេសក្នុងការសិក្សាស្រាវជ្រាវទេសចរណ៍ឱ្យស្របតាមស្តង់ដានិងនិន្នាការអភិវឌ្ឍជាតិ តំបន់ និងអន្តរជាតិ
- រៀបចំគោលនយោបាយ គ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការត្រួតពិនិត្យវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការ យុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ឱ្យចំគោលដៅ និងមានប្រសិទ្ធភាព
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានដែលអាចកើតមានក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់នាយកវិទ្យាស្ថានជាតិទេសចរណ៍។

## ជំពូកទី៨
## អគ្គាធិការដ្ឋាន

**មាត្រា៣០ .-**

អគ្គាធិការដ្ឋាន ជាសេនាធិការឱ្យក្រសួងទេសចរណ៍ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ធ្វើអធិការកិច្ចគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ដោយមានការណែនាំរបស់ប្រធានស្ថាប័ន
- ស្រាវជ្រាវ អង្កេត និងធ្វើអធិការកិច្ចលើប្រតិបត្តិករនិងមូលដ្ឋានអាជីវកម្មទេសចរណ៍ ក្នុងករណីមានភាព មិនប្រក្រតី នៃការប្រកបអាជីវកម្ម សេវាកម្មទេសចរណ៍ ឬការអនុវត្តផ្ទុយទៅនឹងច្បាប់និងបទប្បញ្ញត្តិផ្សេងៗក្នុងវិស័យទេសចរណ៍
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការចាត់វិធានការលើភាពមិនប្រក្រតីក្នុងវិស័យទេសចរណ៍
- ធ្វើអធិការកិច្ចលើទីកន្លែងប្រកបអាជីវកម្មលើទីបរិវេណឬសម្ភារៈដែលបានប្រើប្រាស់ឬសង្ស័យថាបានប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្មទេសចរណ៍និងដែលបានប្រើប្រាស់ឬដែលបានសង្ស័យថាបានប្រើប្រាស់ផ្ទុយនឹងច្បាប់
- ពិនិត្យនិងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- កសាងសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសទេសចរណ៍ទៅតុលាការ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី។

អគ្គាធិការដ្ឋានត្រូវដឹកនាំដោយអគ្គាធិការមួយរូប និងមានអគ្គាធិការរងមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៩
## នាយកដ្ឋាននីតិកម្ម

**មាត្រា៣១ .-**

នាយកដ្ឋាននីតិកម្ម មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យទេសចរណ៍និងបទប្បញ្ញត្តិផ្សេងៗលើការងារទេសចរណ៍ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវលើច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធលើការគ្រប់គ្រងនិងអភិវឌ្ឍវិស័យទេសចរណ៍
- ធ្វើបច្ចុប្បន្នកម្មនិងសិក្សាវាយតម្លៃលើផលប៉ះពាល់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- សហការធ្វើវិសោធនកម្មច្បាប់និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យទេសចរណ៍
- ចងក្រង បោះពុម្ព និងតម្កល់ឯកសារបទដ្ឋានគតិយុត្តទេសចរណ៍នានា
- ផ្សព្វផ្សាយនិងតាមដានការអនុវត្តច្បាប់ស្តីពីទេសចរណ៍និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យទេសចរណ៍
- រៀបចំវគ្គបណ្តុះបណ្តាល អប់រំទាក់ទងទៅនឹងការងារនីតិកម្មក្នុងវិស័យទេសចរណ៍

- សម្របសម្រួល ផ្សះផ្សា និងដោះស្រាយវិវាទទេសចរណ៍ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងទេសចរណ៍និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ត្រួតពិនិត្យ តាមដានលើសកម្មភាពអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី។

នាយកដ្ឋាននីតិកម្មត្រូវដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១០
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៣២ .-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងជាអង្គភាពចំណុះផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដែលទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១១
## អង្គភាពមូលដ្ឋាន

**មាត្រា៣៣ .-**

នៅតាមរាជធានី ខេត្តនីមួយៗមានមន្ទីរទេសចរណ៍រាជធានី ខេត្ត ដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង។

នៅតាមក្រុង ស្រុក ខណ្ឌនីមួយៗមានការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌចំនួនមួយដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង ក្រោមការគ្រប់គ្រងរបស់មន្ទីរ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរទេសចរណ៍រាជធានី ខេត្ត និងការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី១២
## គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាលក្រសួងទេសចរណ៍

**មាត្រា៣៤ .-**

ក្រសួងទេសចរណ៍មានគ្រឹះស្ថានសាធារណៈដែលស្ថិតក្រោមឱវាទរបស់ខ្លួន ទទួលបន្ទុកជាជំនួយដល់ក្រសួងទេសចរណ៍ក្នុងការសិក្សាស្រាវជ្រាវ សិក្សាទីផ្សារ និងផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជា អប់រំ និងបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងប្រមូលចំណូលទេសចរណ៍។ គ្រឹះស្ថានសាធារណៈទាំងនោះរួមមាន៖

- ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍
- សាកលវិទ្យាល័យទេសចរណ៍និងបដិសណ្ឋារកិច្ច/

- សាលាវិជ្ជាជីវៈទេសចរណ៍
- គ្រឹះស្ថានអង្គរ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានសាធារណៈទាំងនោះ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។ គ្រឹះស្ថានសាធារណៈដទៃទៀតអាចនឹងត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់ យោងទៅតាមតម្រូវការនិងស្ថានការណ៍វិវឌ្ឍនៃវិស័យទេសចរណ៍នៅកម្ពុជា។

គ្រឹះស្ថានសាធារណៈនានាដែលស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងទេសចរណ៍ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី១៣
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា៣៥ .-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី១៤
## អន្តរប្បញ្ញត្តិ

**មាត្រា៣៦ .-**

លិខិតបទដ្ឋានគតិយុត្តនានាដែលកំពុងអនុវត្ត ត្រូវបន្តសុពលភាពអនុវត្ត រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

**មាត្រា៣៧ .-**

ការរៀបចំនិងការប្រព្រឹត្តទៅថ្នាក់ក្រោមនាយកដ្ឋាននិងអង្គភាពនានាចំណុះនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា៣៨ .-**

អនុក្រឹត្យនេះនិរាករអនុក្រឹត្យនានាដូចខាងក្រោម៖

- អនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- អនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍
- អនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០២ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានស្ថិតិនិងព័ត៌មានទេសចរណ៍នៃក្រសួងទេសចរណ៍

- អនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងទេសចរណ៍
- អនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ខែ ឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៦
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

# អង្គការលេខរបស់ក្រសួងទេសចរណ៍

- **រដ្ឋមន្ត្រី**
  - **ខុទ្ទកាល័យ – ទីប្រឹក្សា**
  - **គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**
  - **គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**
  - **គណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត**
  - **គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍**
  - **រដ្ឋលេខាធិការ**
    - **អនុរដ្ឋលេខាធិការ**

**អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**
- នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
- នាយកដ្ឋានធនធានមនុស្ស
- នាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ
- នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ

**អគ្គាធិការដ្ឋាន**
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
  - ការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌ

**អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ**
- នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍
- នាយកដ្ឋានវិនិយោគទេសចរណ៍
- នាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
- នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស

**អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍**
- នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ
- នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- នាយកដ្ឋានគ្រប់គ្រងសេវាកម្មកម្សាន្ត និងកីឡាទេសចរណ៍
- នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
- នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ
- នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត
- នាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង

**វិទ្យាស្ថានជាតិទេសចរណ៍**
- នាយកដ្ឋានស្ថិតិទេសចរណ៍
- នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍

**ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍**

**សាកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច**

សាលាវិជ្ជាជីវៈទេសចរណ៍

គ្រឹះស្ថានអង្គរ

អង្គភាពព្រួតពិនិត្យហិរញ្ញវត្ថុ